សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០៤ លេខ ៦៦៥ ចេញផ្សាយថ្ងៃ ពុធ ទី ២៦ ខែ ឧសភា ឆ្នាំ ២០១០


## គណបក្សសមរង្ស៊ីស្នើសុំ ខេង ម្ដងទៀតដើម្បីទៅសួរសុខទុក្ខលោកស្រី មាស ស្រី និងលោក ព្រាំ ជា



លោកស្រី កែ សុវណ្ណរតន៍



អ្នកស្រី មាស ស្រី មុនពេលចាប់ខ្លួនដាក់ពន្ធនាគារដោយសារការដកបង្គោលតម្រុយពីដីស្រែ

ដោយ : ជ័យ តារា

អគ្គលេខាធិការ គណបក្សសម រង្ស៊ី បានស្នើជាលើកទី៣ ហើយ ទៅអាជ្ញាធរ នៃស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យគណៈប្រតិភូគណបក្សសមរង្ស៊ី បានចូលជួប សួរសុខទុក្ខលោកស្រី *មាស ស្រី* និងលោក *ព្រាំជា*ជាប្រជាកសិករ

តទៅទំព័រទី៤ ឡ

## គេនិយាយពីការបង្ក្រាបបាតុករនៅសៀម តែភ្លេចនិយាយពីការបង្ក្រាបបាតុករនៅកម្ពុជានិងភូមា



សកម្មភាពបង្ក្រាបព្រះសង្ឃខ្មែរពីសំណាក់អាជ្ញាធរខ្មែរ និងសកម្មភាពបង្ក្រាបសង្ឃភូមាពីសំណាក់អាជ្ញាធរភូមា

ដោយ : សីហា

កាលពី១២ឆ្នាំមុនគឺខែសីហា ឆ្នាំ១៩៩៨, អាជ្ញាធរខ្មែរ បាន បង្ក្រាបដោយបង្ហូរឈាមទៅលើ ហ្វូងបាតុករ ដែលដឹកនាំដោយ លោក*សម រង្ស៊ី* ប្រធានគណ បក្សសម រង្ស៊ី ប្រឆាំងទៅនឹង លួចបន្លំសន្លឹកឆ្នោត ។ បាតុកម្ម

តទៅទំព័រទី២ ស


ក្រុមហ៊ុនសំណង់ ថៃ ឡាគី នីហរ័ណ អាហរ័ណ

THAY-LAKY IMPORT EXPORT AND CONSTRUCTION Co.,Ltd

ក្រុមហ៊ុនមានទទួលសេវា ដូចតទៅ :

- សាងសង់សំណង់គ្រប់ប្រភេទ (អគារ សណ្ឋាគារ រោងចក្រឧស្សាហកម្ម ឃ្លាំង ភូមិគ្រឹះ ផ្ទះល្វែង ស្ពាន ថ្នល់ ...) ។
- សិក្សាគំរោង គូរប្លង់ គ្រឿងបង្គំ ស្ថាបត្យកម្ម ដោយកុំព្យូទ័រ ។
- លក់ ជួល ទិញ ផ្ទះ និង ដី ។
- ដំឡើងបណ្ដាញអគ្គិសនី ។
- ផលិតគ្រោងដែកសំណង់ ។
- ទីប្រឹក្សាត្រួតពិនិត្យសំណង់ ។

ក្រុមហ៊ុនប្រជុំដោយ **អតីតសាស្ត្រាចារ្យ** វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ) វិស្វករសំណង់ស៊ីវិល ស្ថាបត្យករ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំ សាងសង់ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ។ សំណង់របស់លោកអ្នកប្រាកដជាមានភាពរឹងមាំ មានសោភ័ណភាពប្រកបទៅដោយ ផាសុកភាព និងមានសុភមង្គល ។

អាស័យដ្ឋានផ្ទះលេខ ៨ ផ្លូវលេខ ៦១៨ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

Tel : (012) 954 606, (011) 527 767, (012) 862 515
: (012) 734 083, (012) 991 883, (012) 255 435
E-mail : thaylakyconstruction@yahoo.com
U.S.A : 5663 CHERRY AVE LONG BEACH, CA 908O5
E-mail : tanvuthay@verizon.net


## គង់ គាំ ថា ឱម យ៉ិនទៀង គួរតែងតាំងជាប្រធានអង្គភាពការពារជនពុករលួយវិញល្អជាង



លោក គង់ គាំ ប្រធានស្ដីទីគណបក្សសមរង្ស៊ី



លោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

ដោយ : សុរិយាវិរិយ៍

អង្គការជាតិ អន្តរជាតិធំៗ ក៏ដូចជា មន្ត្រីគណបក្សសម រង្ស៊ី បានរិះគន់ ការតែងតាំងលោក *ឱម យ៉ិនទៀង* ជាប្រធានអង្គភាព ប្រឆាំងអំពើពុករលួយ ។ អ្នកខ្លះថារដ្ឋាភិបាលកម្ពុជាមិនគួរតែងតាំងអ្នកនយោបាយ ឬអ្នកដែលពាក់ព័ន្ធ នឹងអំពើពុករលួយ ឱ្យកាន់ស្ថាប័ន ប្រឆាំងអំពើពុករលួយនោះទេ ពីព្រោះ

តទៅទំព័រទី៤ ម

## រដ្ឋសភាបោះឆ្នោតផ្លាស់ប្ដូរសមាជិកគណៈរដ្ឋមន្ត្រីចំនួន១១រូបនៅថ្ងៃស្អែកនេះ

### មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនបើកកិច្ចប្រជុំជាប្រញាប់មួយនៅទីស្នាក់ការគ-៨៥កាលពីរសៀលម្សិលមិញ



លោក សុន ឆ័យ ប្រធានក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី



លោក ហ៊ុន សែន និងសមាជិកគណៈរដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលរបស់គាត់

ដោយ : វាសនា

នៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែឧសភា ឆ្នាំ២០១០ ស្អែកនេះរដ្ឋសភា នឹងបើកសម័យប្រជុំពេញអង្គមួយ ដើម្បីបន្តពិភាក្សា និងអនុម័ត ទៅលើរបៀបវារៈបន្តពីលើកមុនគឺរបៀបវារៈទី៩ដល់ទី១២ ។

របៀបវារៈទី១០ នៃកិច្ចប្រជុំនោះ គឺការបោះឆ្នោត ទុកចិត្តលើសមាសភាព រាជរដ្ឋាភិបាល

តទៅទំព័រទី២ ន

## GlobalWitness : ការស៊ើបអង្កេតអំពើពុករលួយកម្រិតខ្ពស់ក្នុងជួររដ្ឋាភិបាលបង្ហាញថា លី យ៉ុងផាត់ ទទួលខុសត្រូវសំខាន់ជាងគេ



ឧកញ៉ា លី យ៉ុងផាត់ ដែលមានរឿងអាស្រូវពាក់ព័ន្ធដីធ្លី និងការប្លន់ខ្សាច់



ឧកញ៉ា ម៉ុង ឫទ្ធី ពេលទទួលបានគ្រឿងឥស្សរិយយសពីនាយករដ្ឋមន្ត្រី



ប្រជាពលរដ្ឋនៅឃុំអមលាំង ពេលតវ៉ានឹងក្រុមហ៊ុនឧកញ៉ា លី យ៉ុងផាត់



ប្រជាពលរដ្ឋឧត្ដរមានជ័យត្រូវបានអាជ្ញាធរបណ្ដេញចេញដើម្បីយកដីប្រគល់ឱ្យក្រុមហ៊ុនស្ករស

ដោយ : គ.អរពិន្ទ

ឧកញ៉ា *លី យ៉ុងផាត់* ដែលបានក្លាយទៅជាសមាជិកព្រឹទ្ធសភារបស់គណបក្សប្រជាជន ត្រួតត្រាប្រទេសកម្ពុជាបានអះអាងថា ក្រុមហ៊ុនខ្លះគ្រាន់តែឈរឈ្មោះឱ្យអ្នកវិនិយោគទុនបរទេសដូចជាក្រុមហ៊ុនដាំអំពៅនៅឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុងជារបស់ថៃ ក្រុមហ៊ុននៅអូរស្មាច់ឧត្ដរមានជ័យគឺ

តទៅទំព័រទី២ ៩


## ដំណឹងលក់ដី

យើងខ្ញុំមានដីមួយកន្លែងទំហំ ៣០ម x ៣០ម នៅទល់មុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ ទីតាំងដីនោះនៅចម្ងាយប្រមាណ៥០០ម៉ែត្រពីភ្លើងស្តុបព្រលានយន្តហោះ ជាប់កាច់ជ្រុងផ្លូវបេតុង ស្ថិតនៅក្នុងភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានទឹក និងភ្លើងរដ្ឋ។

ទីតាំងនៃដីនោះស្ថិតនៅទីប្រជុំជន មានផ្សារ រោងចក្រ អាចធ្វើផ្ទះសំណាក់ ខុនដូ ហើយលក់ក្នុងតម្លៃ ៦៥ម៉ឺនដុល្លារអាមេរិក ដែលជាតម្លៃអាចនិយាយចរចាគ្នាបាន។ បើអតិថិជនចាប់អារម្មណ៍ សូមទំនាក់ទំនងទូរស័ព្ទលេខ **០១៦ ២៩ ៥៦ ៥៦**។

សូមអរគុណ


## សង្គមស៊ីវិលរិះគន់កម្លាំងប្រដាប់អាវុធដែលការពារក្រុមហ៊ុនតែមកបង្ក្រាបរាស្ត្រ

ដោយ : មុត ស្រួច

ទន្ទឹមនឹងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋនៅឃុំ អមលាំង ដែលកំពុងប្រឈមមុខនឹងការបាត់បង់ដីធ្លីដោយសារការរឹបអូសឆៅៗពីសំណាក់ក្រុមហ៊ុនស្ករសភ្នំពេញរបស់លោក*លី យ៉ុងផាត់* នោះ មន្ត្រីការពារសិទ្ធិមនុស្សក៏បានសម្ដែងនូវការមិនពេញចិត្ត ចំពោះការបញ្ជូនទាហានកាន់តែច្រើនឡើងៗមកការពារដីឱ្យឈ្មួញដែរ។

មានសេចក្ដីរាយការណ៍មួយបានឱ្យយើងដឹងថា ក្រុមហ៊ុនស្ករសភ្នំពេញរបស់ឧកញ៉ា *លី យ៉ុងផាត់* សមាជិកព្រឹទ្ធសភា នៃគណបក្សប្រជាជនកម្ពុជាមិនដឹងជាត្រូវដងត្រូវផ្លែជាមួយទាហាន ឬយ៉ាងណានោះទេ ស្រាប់តែមកដល់តំណាក់កាលចុងក្រោយនេះគេឃើញទាហានលើកគ្នាកាន់តែច្រើនឡើងៗចូលមកដល់ដីកំពុងមានជម្លោះ ខណៈពេលដែលប្រជាពលរដ្ឋជាង៦០០០នាក់ក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កំពុងធ្វើ

តទៅទំព័រទី៣ ខ

*បរិយាយថ្ងៃនេះ*

## ជម្លោះដីធ្លីរវាងក្រុមហ៊ុនខេប៊ីស៊ីជាមួយរាស្ត្រខេត្តកំពង់ឆ្នាំងមិនពិបាកដោះស្រាយទេ

ដោយ : ហង្ស ប្រាជ្ញា

បញ្ហាជម្លោះដីធ្លីកើតមានតាមតំបន់នានា ហើយដែលប្រការដ៏លេចធ្លោបំផុតនោះគឺប្រជារាស្ត្រតាមសហគមន៍ទាំងឡាយកំពុងបន្តប្រយុទ្ធយ៉ាងត្រដាបត្រដួសតទល់នឹងឥទ្ធិពលដ៏ខ្លាំងនៃពួកអ្នកមានអំណាចតំណែងធំៗក្នុងជួររដ្ឋាភិបាល អំណាចអាវុធ ទាំងឥទ្ធិពលលុយកាក់របស់ក្រុមហ៊ុនឯកជន

តទៅទំព័រទី៤ ក

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០២**
Tel: 017 360 678 , E-mail: kmsnews@gmail.com

**តមកពីទំព័រទី១ ន**

កែសម្រួលចំនួន១១រូប ។

ប៉ុន្មានម៉ោង បន្ទាប់ពីរបៀបវារៈនេះ បានដល់ដៃ សមាជិកសភា តាមរយៈលិខិត អញ្ជើញរបស់លោក*ហេង សំរិន* ប្រធានរដ្ឋសភា កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០នោះ មានសេចក្ដីរាយការណ៍ថា ថ្នាក់ដឹកនាំគណបក្សប្រជាជន បានបើកកិច្ចប្រជុំ ជាបន្ទាន់មួយដែរ នៅទីស្នាក់ការកណ្ដាល គ-៨៥ ចំការមន ។ កិច្ចប្រជុំជាសម្ងាត់ និង មិនបានគ្រោងទុក្ខ ជាមុននេះ ត្រូវបានគេសង្ស័យថា ជាការពិភាក្សា ទៅលើការ កែសម្រួលសមាជិកគណៈរដ្ឋមន្ត្រី ចំនួន១១រូប ដែលក្នុងនោះ ក៏មានការផ្លាស់ប្ដូររដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៅតាមក្រសួងជាច្រើននាក់ផងដែរ ។ ក៏ប៉ុន្តែមិនទាន់មាន សេចក្ដីរាយការណ៍ផ្លូវការណាមួយបញ្ជាក់អំពីឈ្មោះរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលត្រូវផ្លាស់ប្ដូរនោះទេ ។

លោក*សុនឆ័យ* ប្រធានក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានមានប្រសាសន៍ ពាក់ព័ន្ធទៅនឹងការកែសម្រួលសមាជិក គណៈរដ្ឋមន្ត្រី ទាំង១១រូប នេះថាលោកមិនទាន់ទទួលបានឯកសារ ជាក់លាក់ ថាតើមន្ត្រីណា ដែលត្រូវផ្លាស់ប្ដូរនោះទេ, ប៉ុន្តែលោកថ្លែងថា ការផ្លាស់ប្ដូររដ្ឋលេខាធិការ ក្រសួងការពារជាតិម្នាក់ កូតាហ្វ៊ុនស៊ិនប៉ិច គឺលោកឧត្ដមសេនីយ៍ *ហ៊ុន ភឿង* នោះមិនត្រឹមត្រូវទេ បើសិនជាការផ្លាស់ប្ដូរនេះ សំអាងថាគាត់គាំទ្រគណបក្សប្រឆាំងនោះ ។

លោក*សុនឆ័យ* បានមានប្រសាសន៍ថា "*ឃើញមាន ការបញ្ជាក់ ជាសាធារណៈ អំពីរដ្ឋលេខាធិការក្រសួងការពារជាតិម្នាក់ដែលដកតួនាទីនោះដោយសារតែគាត់ ទាក់ទងមក គណបក្សប្រឆាំង ។ ប៉ុន្តែខ្ញុំយល់ថា បើសិនជា ហេតុផល ផ្លាស់ប្ដូរមន្ត្រីនេះ ដោយសារតែគេមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង, ខ្ញុំយល់ថាជាការខុសឆ្គងមួយធ្ងន់ធ្ងរណាស់ ពីព្រោះ ប្រទេសកម្ពុជាយើង កាន់លទ្ធិប្រជាធិបតេយ្យគឺលើកលែងតែគេធ្វើអ្វីមួយ ដែលប៉ះពាល់ ដល់ផលប្រយោជន៍ជាតិ,ក៏ប៉ុន្តែការទាក់ទងរវាងមន្ត្រីគណបក្សមួយជាមួយ គណបក្សមួយ ជារឿងធម្មតា នៅក្នុងសង្គមប្រជាធិបតេយ្យ*" ។

លោក*សុន ឆ័យ*បានមានប្រសាសន៍ថារដ្ឋាភិបាលគួរតែមានគណៈកម្មការឯករាជ្យមួយក្នុងការស៊ើបអង្កេត ទៅលើសមាជិកគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការវាយតម្លៃក្នុងការផ្លាស់ប្ដូរ ។ ជាមួយគ្នានោះដែរ លោកចង់ឱ្យមានការផ្លាស់ប្ដូររដ្ឋមន្ត្រី រយៈពេល៥ឆ្នាំ ឬមួយអាណត្តិម្ដង ដើម្បីកុំឱ្យរដ្ឋមន្ត្រីខ្លះ ដែលកាន់តំណែងដុះស្លែ ប្រើប្រាស់តួនាទីអំណាចរបស់ខ្លួន ធ្វើផ្ដេសផ្ដាស ដូចជាប្រមូលប្រពន្ធ កូនអោយកាន់តួនាទី ពុករលួយ នៅក្នុងក្រសួងនោះ ។ ការថ្លែងរបស់លោក*សុន ឆ័យ* នេះ មិនបានបញ្ចេញឈ្មោះ មន្ត្រីណាទេ តែគេជឿថា លោកនិយាយសំដៅលោក*ចម ប្រសិទ្ធ* រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ដែលល្បីថាកូនប្រុស ស្រី និងប្រពន្ធរបស់គាត់ក៏មានតួនាទី ខ្ជីមខ្ជាញ់ នៅក្នុងក្រសួងនោះដែរ ហើយលោក*ហោ ណាំហុង* ក៏ត្រូវបានគេដឹងថា មានកូនចៅស្នេកស្ទះធ្វើការនៅក្រសួងការបរទេសដែរ ។

លោក*សុន ឆ័យ* បានបញ្ជាក់ផងដែរថា ចំពោះមន្ត្រី និងរដ្ឋមន្ត្រីណា ដែលមិនឆ្លើយសំណួរអ្នកតំណាងរាស្ត្រ ឱ្យស្របតាមរដ្ឋធម្មនុញ្ញនោះ ក៏គួរតែគណៈកម្មការឯករាជ្យ ពិចារណាក្នុងការដាក់ទណ្ឌកម្មដូចជាការដកតួនាទីជាដើម ។

រយៈពេលចុងក្រោយនេះប្រមុខរដ្ឋាភិបាល បានបញ្ជាឱ្យទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ។ បទបញ្ជានោះ ក៏បានឈានដល់ការដកហូតតំណែង លោក *ទី សុគន្ធ* អគ្គនាយករដ្ឋបាល ព្រៃឈើ និងមន្ត្រីតូចតាចមួយចំនួនទៀតផងដែរ ។ បញ្ហាព្រៃឈើនេះ ក៏ស្ថិតនៅក្រោមការទទួលខុសត្រូវ របស់លោក*ច័ន្ទ សារុន* រដ្ឋមន្ត្រី ក្រសួងកសិកម្មដែរ ។ ដូច្នេះការកែសម្រួល សមាជិកគណៈរដ្ឋមន្ត្រីចំនួន១១នាក់នេះ ក៏អាចធ្វើឱ្យមន្ត្រីខ្លះ នៅក្រសួងកសិកម្មព្រួយបារម្ភ នឹងការដកចេញដែរ ។

ចំណែកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលវិញ ក៏មានរឿងអាស្រូវដែរ ដូចជាមាន របាយការណ៍ របស់អង្គការ Global Witness បញ្ជាក់ថាឧកញ៉ាចំនួន ២រូប ទទួលបានអាជ្ញាប័ណ្ណ ពីរដ្ឋាភិបាល ក្នុងការបូមខ្សាច់ពីសមុទ្រខ្មែរ នៅឯខេត្តកោះកុង យកទៅលក់ឱ្យប្រទេសសិង្ហបុរី ដែលមានតម្លៃ ដល់ទៅរាប់រយលានដុល្លារក្នុងមួយឆ្នាំៗ ដែលបញ្ហានេះ ក៏អាចធ្វើឱ្យមន្ត្រីនៅក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាពិសេស លោករដ្ឋមន្ត្រី*ស៊ុយ សែម* ក៏គួរតែស្ថិតនៅក្នុងចំណោម បេក្ខភាព កែសម្រួលសមាជិកគណៈរដ្ឋមន្ត្រី ដែលគ្រោងនឹងធ្វើ នៅថ្ងៃស្អែកនេះដែរ ។

រឿងអាស្រូវ ដែលធ្វើអោយប៉ះពាល់កិត្តិយស មុខមាត់រដ្ឋាភិបាលធ្ងន់ធ្ងរ រយៈពេល ចុងក្រោយនេះគឺការធ្លាយចេញនូវប្រាក់ ដែលផ្ដល់ឱ្យ ដោយក្រុមហ៊ុនប្រេងតូតាល់ ដល់មន្ត្រីខ្មែរ ចំនួន២៨លានដុល្លារ ជាថ្នូរនឹងការទទួលបានសិទ្ធិ រុករកប្រេងនៅបាតសមុទ្រខ្មែរនិងក្រុមហ៊ុនបរទេសមួយទៀត ដែលផ្ដល់ប្រាក់២.៥លានដុល្លារ ជាថ្នូរសំរាប់រករ៉ែ នៅខេត្តភាគឦសាន ប្រទេសកម្ពុជា ។

ប៉ុន្តែមន្ត្រីរដ្ឋាភិបាល បានឱ្យដឹងថា ប្រាក់នោះត្រូវបានដាក់បញ្ចូល នៅក្នុងមូលនិធិសង្គម ដែលមូលនិធិនេះត្រូវបានគេដឹងថា បានរំលាយចោល កាលពីប៉ុន្មានឆ្នាំមុនហើយនោះ ។

ដូច្នេះអ្នកដែលពាក់ព័ន្ធ ទៅនឹងរឿងអាស្រូវទាំងនេះ គួរតែមាននៅក្នុងបញ្ជី បេក្ខភាព នៃការកែសម្រួល សមាជិកគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៧ ឧសភា ឆ្នាំ២០១០ស្អែកនេះ ។

ទោះជាយ៉ាងណាគេមិនទាន់ដឹងជាផ្លូវការថា តើមន្ត្រី ឬរដ្ឋមន្ត្រីណា ដែលនឹងត្រូវដកចេញពីតួនាទីក្រោមពាក្យ ដែលថាកែសម្រួល សមាជិក គណៈរដ្ឋមន្ត្រីនោះទេ ហើយលទ្ធផលនៃកិច្ចប្រជុំ របស់ថ្នាក់ដឹកនាំគណបក្សប្រជាជន កាលពីរសៀលម្សិលមិញនេះ ក៏មិនបានអោយដឹងជាសាធារណៈភ្លាមៗដែរ ៕

---

**តមកពីទំព័រទី១ ៩**

គាត់គ្រាន់តែចេញមុខឈរឈ្មោះឱ្យគេ ថ្វីបើគាត់មិនបានបញ្ជាក់ប្រាប់ថា ម្ចាស់ក្រុមហ៊ុននោះជានរណា វាំលែងតែក្រុមហ៊ុនដាំអំពៅនៅខេត្តកំពង់ស្ពឺដែលគាត់បានសារភាពថា ជារបស់គាត់នោះ។

ឧកញ៉ា *លី យ៉ុងផាត់* បាននិយាយថា "*ខ្ញុំជំរាបរឿងនៅអូរស្មាច់ មិនមែនរបស់ខ្ញុំទេ របស់ក្រុមហ៊ុនគេទេ ... គេមករកខ្ញុំ គេទុកចិត្តខ្ញុំ ខ្ញុំជួយគេទៅ រឿងដីសម្បទានដីធ្លី ។រឿងក្រុមហ៊ុនរបស់គេទេ មិនមែនរបស់ខ្ញុំទេ ។ រឿងនៅឃុំជីខលើស្រុកស្រែអំបិល ខេត្តកោះកុងរបស់ក្រុមហ៊ុនថៃទេ* " ។

នេះជាការថ្លែងអធិប្បាយដល់ករណីនៃដីធ្លីមួយកន្លែង១ជិត១ម៉ឺនហិកតាដែលកាន់កាប់ដោយក្រុមហ៊ុនរបស់លោក *លី យ៉ុងផាត់* ហើយប្រឈមឈ្លោះនឹងប្រជារាស្ត្រតាមសហគមន៍នានាដែលចេញមុខតវ៉ាការពារដីធ្លីស្រែចំការអាយុជីវិតរបស់គាត់នោះ។

ឧកញ៉ា *លី យ៉ុងផាត់* បាននិយាយទៀតថា វាមានបញ្ហាដែល "*យើងមិនអាចទៅលូកលាន់គេបានទេ ពីព្រោះការងាររបស់គេ ។ នៅកំពង់ស្ពឺអាហ្នឹងជារបស់ខ្ញុំផ្ទាល់ អត់មានរបស់ក្រុមហ៊ុនណាទេ របស់ខ្ញុំផ្ទាល់*" ជាការថ្លែងដល់ដីជាង៩ពាន់ហិកតាដែលក្រុមហ៊ុនរបស់ឧកញ៉ា *លី យ៉ុងផាត់* នេះកំពុងឈ្លោះជាមួយប្រជាជននៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងនៅមិនទាន់មានដំណោះស្រាយស្រេចបាច់នៅឡើយនោះ។

ប៉ុន្តែសម្រាប់កញ្ញា *អេឡេន័រ ទីកូល* ជាមន្ត្រីយុទ្ធនាការស្រាវជ្រាវទទួលបន្ទុកតំបន់អាស៊ីនៃអង្គការ Global Witness ដែលធ្វើសកម្មភាពតាមដានដោយការផ្ដល់មូលនិធិទ្រទ្រង់ពីប្រទេសអ្នកមានធំៗនោះមន្ត្រីបរិស្ថានពិភពលោកនេះបាននិយាយអះអាងអំពីការស្រាវជ្រាវរបស់អង្គការខ្លួន។

កញ្ញា*អេឡេន័រ ទីកូល* បានអធិប្បាយថា ក្រៅពីក្រុមហ៊ុនកសិឧស្សាហកម្មដែលកាន់កាប់ដីរាប់សិបម៉ឺនហិកតានៅកម្ពុជាដែលផ្ទុយនឹងច្បាប់អនុញ្ញាតរបស់កម្ពុជាខ្លួនឯងនោះ លោក *លី យ៉ុងផាត់* មានក្រុមហ៊ុនកាស៊ីណូ សណ្ឋាគារជាច្រើនកន្លែងទៀត។

កញ្ញា *អេឡេន័រ* បានមានប្រសាសន៍យ៉ាងនេះអំពីមេឈ្មួញកំពូលសេដ្ឋីស្ដុកស្ដម្ភម្នាក់ជាសមាជិកព្រឹទ្ធសភាគណបក្សប្រជាជនលោក *លី យ៉ុងផាត់* "*តាមការស៊ើបអង្កេតរបស់យើងនូវអំពើពុករលួយកម្រិតខ្ពស់នៅកម្ពុជានោះ យើងរកឃើញថាលោកលី យ៉ុងផាត់ ដើរតួយ៉ាងសំខាន់នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ។ យើងក៏បានដឹងដែរថាគាត់មានសណ្ឋាគារយ៉ាងច្រើនមានក្រុមហ៊ុនកសិឧស្សាហកម្មក្រុមហ៊ុនសំណង់ ក្រុមហ៊ុនអគ្គិសនី បនល្បែងស៊ីសងនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ*" ។

ហើយជាការបញ្ជាក់នូវអ្វីជាអាជីវកម្មដែលរងការទិទៀនពីមជ្ឈដ្ឋានប្រជារាស្ត្ររងគ្រោះក៏ដូចជាអ្នកបរិស្ថានពិភពលោកទាំង Global Witness កញ្ញា*អេឡេន័រទីកូល*បានកត់សម្គាល់ថា "*កាលឆ្នាំ២០០៨យើងបានរកឃើញក្រុមហ៊ុនលីយ៉ុងផាត់បានកាន់កាប់ផ្ដាច់មុខនូវអាជីវកម្មបូមខ្សាច់នៅខេត្តកោះកុងរកចំណូលបានយ៉ាងសម្បើម ហើយពួកអ្នកភូមិបានធ្វើការតវ៉ាដោយសារថាការបូមខ្សាច់សមុទ្រនោះប៉ះពាល់ដល់មុខរបរនេសាទរបស់ពលរដ្ឋខ្មែរនិងជីវភាពប្រចាំថ្ងៃរបស់ពួកគាត់*" ។

មន្ត្រី Global Witness រូបនេះបានថ្លែងអះអាងតាមការស្រាវជ្រាវនោះទៀតថា ខ្សាច់ដែលក្រុមហ៊ុនលីយ៉ុងផាត់បានបូមដោយមានការជំទាស់ពីប្រជារាស្ត្រនោះ ក្រុមហ៊ុនឯកជនដែលមានទំនាក់ទំនងជាមួយគណបក្សកាន់អំណាចនៅកម្ពុជាបានដឹកខ្សាច់នោះលក់ទៅឱ្យប្រទេសយួន ប្រទេសម៉ាឡេស៊ីនិងប្រទេសសឹង្ហបុរី ។

នាង *អេឡេន័រ ទីកូល* បានលើកឡើងនូវសំណួរយ៉ាងនេះថាបើមានការបំផ្លាញហិនហោចនូវធនធានរបស់ប្រទេសកម្ពុជានេះយកទៅលក់ដូរដោយមិនផ្ដល់ប្រយោជន៍អ្វីដល់ប្រជាពលរដ្ឋខ្មែរផងនោះ សួរថា តើប្រទេសកម្ពុជានឹងវិវឌ្ឍន៍ទៅយ៉ាងម៉េចនាអនាគត ?

ប៉ុន្តែសម្រាប់លោក*លីយ៉ុងផាត់* នោះថា ការបូមខ្សាច់ដោយក្រុមហ៊ុនរបស់គាត់លក់ទៅឱ្យប្រទេសសឹង្ហបូរី... នោះគឺជាការស្ដារព្រែកដើម្បីបង្ការគ្រោះទឹកជំនន់ដែលនៅរដូវវស្សាលិចលង់ផ្លូវ ភូមិអ្នកស្រុក និងធ្វើឱ្យខូចខាតផ្ទះសម្បែងរបស់ពលរដ្ឋ។

លោក *លី យ៉ុងផាត់* បាននិយាយថា "*ខ្ញុំគិតគូរដល់រឿងហ្នឹង ហើយក៏បានស្នើសុំរាជរដ្ឋាភិបាលថានិយាយរួមថាវាហេងក៏ថាបានដែរ ។ បើស្ដារព្រែកយើងអត់មានលុយណាស្ដារទេ ។ ឆ្លៀតឱកាសនេះគេត្រូវការខ្សាច់យើងឱ្យគេស្ដារព្រែក គេយកខ្សាច់ យើងក៏លក់ខ្សាច់ទៅ*" ។

អង្គការ Global Witness បានធ្វើការស្រាវជ្រាវយ៉ាងលំអិតនិងបានបញ្ចេញរបាយការណ៍ផ្អែកលើមូលដ្ឋាន នៃការស៊ើបអង្កេតច្បាស់លាស់របស់ខ្លួនថ្លែងបរិហារការដែលរដ្ឋាភិបាលលោក *ហ៊ុន សែន* បានបើកដៃឱ្យក្រុមហ៊ុនឯកជនទាំងឡាយបូមខ្សាច់នៅសមុទ្រកម្ពុជារាប់ទាំងក្រុមហ៊ុនលីយ៉ុងផាត់ ក្រុមហ៊ុនម៉ុងឫទ្ធី និងក្រុមហ៊ុនផ្សេងទៀត ។ រឿងនេះបានបង្ខំចិត្តឱ្យលោក *ហ៊ុន សែន* ក្នុងនាមជានាយករដ្ឋមន្ត្រីប្រកាសលុបចោលនូវអាជ្ញាប័ណ្ណជាមួយក្រុមហ៊ុនដទៃទៀតលើកលែងតែក្រុមហ៊ុនពីរ គឺរបស់ឧកញ៉ាមេឈ្មួញ*ម៉ុង ឫទ្ធី* និងឧកញ៉ា *លី យ៉ុងផាត់* ដែលជាមនុស្សជិតដិតមានផលប្រយោជន៍ជាមួយពួកអ្នកកាន់អំណាចនោះ។

សមាជិកព្រឹទ្ធសភាគណបក្សប្រជាជន *លី យ៉ុងផាត់* នេះបានទទួលស្គាល់ថា គាត់ជាមនុស្សមានសញ្ជាតិពីរសញ្ជាតិខ្មែរផងនិងសញ្ជាតិសៀមផង ដែលលិខិតឆ្លងដែនសញ្ជាតិសៀមគាត់បានដាក់ឈ្មោះថា *ផាត់ សុផាផា* ដោយលើកនិយាយបរិយាយថា នោះជាឈ្មោះដែលគាត់បានដាក់នៅពេលដែលបានរត់គេចចេញពីការឡើងកាន់កាប់អំណាចរបស់របបប៉ុលពតដោយបានចូលជាសញ្ជាតិថៃនៅឆ្នាំ១៩៩៥។

គាត់បានអះអាងថា គាត់មានស្រុកកំណើតនៅភូមិថ្មស ឃុំថ្មស ស្រុកគិរីសាគរ នៃខេត្តកោះកុង។ យ៉ាងណាក៏ដោយតាមគេហទំព័រនៃសភាពាណិជ្ជកម្មកម្ពុជានោះ លោក *លី យ៉ុងផាត់* មានតួនាទីជាអនុប្រធានស្ថាប័ននេះ ហើយថែមទាំងជាសមាជិកព្រឹទ្ធសភា។ គាត់ក៏ជាម្ចាស់នៃក្រុមហ៊ុនចំនួន៩ ព្រមទាំងជាម្ចាស់នៃកាស៊ីណូមួយចំនួនតាមបណ្ដោយព្រំដែនខ្មែរសៀមផងដែរ៕

---

**តមកពីទំព័រទី១ ស**

ដែលមានអ្នកចូលរួម រាប់ម៉ឺននាក់ និងបានបោះតង់តវ៉ា នៅពីមុខអតីតអគាររដ្ឋសភាដែលក្រុមបាតុករដាក់ឈ្មោះថាជាទីលាន អ្នកប្រជាធិបតេយ្យនោះ បានធ្វើអោយបាតុករបាត់ខ្លួនជាច្រើននាក់ ។

បាតុករជានិស្សិត ជនស៊ីវិល និងព្រះសង្ឃ ដែលបានតវ៉ានៅកម្ពុជាកន្លងមកហើយទទួលរងនូវការបង្ក្រាបដោយបង្ហូរឈាមនេះ គ្មានអាវុធប្រឆាំង ទៅនឹងអាជ្ញាធរ ដូចជាបាតុករអាវក្រហមនៅប្រទេសសៀមទេ ។ ក៏ប៉ុន្តែរបៀបនៃការបង្ក្រាប មានលក្ខណៈដូចគ្នា គឺសមត្ថកិច្ចបានលើកដៃកេះកៃកាំភ្លើង បាញ់សំដៅពលរដ្ឋខ្លួនឯង បង្ហូរឈាមប្រជាពលរដ្ឋខ្លួនឯង នៅលើទឹកដីនៃអាណាចក្រដែលជាបេះដូងនៃប្រទេសរបស់ខ្លួននោះ ។

មហាជនខ្មែរដែលបានមើលឃើញសកម្មភាព ក្រុមទាហានក្រោមបញ្ជា លោក*អាប់ភីស៊ិត វ៉ាចាជីវ៉ា* នាយករដ្ឋមន្ត្រីសៀម បង្ក្រាបទៅលើបាតុករ អាវក្រហមនិយមលោក*ថាក់ស៊ីន ស៊ីណាវ៉ាត្រា* យ៉ាងសាហាវ ដោយទាហាន បានលើកាំភ្លើង បាញ់សំដៅពលរដ្ឋខ្លួនឯងហើយស្រក់ឈាមក្រហមច្រាល នៅលើផ្លូវនៃរាជធានីបាងកកនោះបានធ្វើឱ្យពលរដ្ឋខ្មែរ ជាពិសេស អ្នកទីក្រុងភ្នំពេញបានទឹកឃើញទៅដល់កម្លាំងប្រដាប់អាវុធក្រោមបញ្ជាលោក*ហុក ឡុងឌី* កាលនៅរស់ ជាអគ្គស្នងការ នគរបាលជាតិ បានបង្ក្រាប ទៅលើក្រុមបាតុករជាជនស្លូតត្រង់និងព្រះសង្ឃខ្មែរ ដែលមានតែបាតដៃទទេ ដោយបង្ហូរឈាម ។ ព្រះសង្ឃខ្មែរខ្លះ ត្រូវបានអាជ្ញាធរបាញ់សម្លាប់ និងប្រើប្រាស់រថយន្តបាញ់ទឹកស្អុយ ស្រោចពីលើគ្មានប្រណីឡើយ ។

ចំណែកសកម្មភាពខ្លះទៀតរបស់អាជ្ញាធរ ដែលវាយដំ នឹងដំបង ទាត់ធាក់ ទៅលើព្រះសង្ឃខ្មែរ បាតុករខ្មែរ យ៉ាងសាហាវនោះ នៅមានរូបភាព ជាភស្តុតាងបញ្ជាក់ រហូតដល់សព្វថ្ងៃនេះទៀតផង ។ ដូច្នេះហើយបានជាគេឃើញសកម្មភាព នៃការបង្ក្រាបក្រុមអាវក្រហមនៅទីក្រុងបាងកក កាលពីសប្ដាហ៍មុននោះ បានធ្វើឱ្យអ្នកខ្លះ នឹកឃើញដល់ ប៉ូលិសខ្មែរ បង្ក្រាបលើបាតុករខ្មែរ ជាជនស៊ីវិលនិងព្រះសង្ឃ ដែលមានតែ បាតដៃទទេសាហាវជាងទាហានសៀមទៅទៀត ។ ដូច្នេះសៀម បាននិងកំពុងទទួលបាន នូវការរិះគន់ថា មានភាពសាហាវ នៅក្នុងការបង្ក្រាបបាតុកម្ម ។

នៅក្នុងតំបន់អាស៊ីនេះ មានប្រទេសចំនួន៣ ដែលអាជ្ញាធរបង្ក្រាបទៅលើបាតុករ សាហាវព្រៃផ្សៃបំផុត គឺអាជ្ញាធរខ្មែរ, អាជ្ញាធរភូមា និងអាជ្ញាធរ នៃប្រទេសសៀម ។ ប៉ុន្តែការចាត់វិធានការ របស់លោក *អាប់ភីស៊ិត* ទៅលើបាតុករអាវក្រហមនោះត្រូវបានអាជ្ញាធររកឃើញសព្វាវុធ និងគ្រឿងផ្ទុះជាច្រើនទៀតដែលបាតុករវាយប្រហារទៅលើយោធាមុន ។ ផ្ទុយទៅវិញ បាតុករជាជនស៊ីវិល និងជាព្រះសង្ឃនៅប្រទេសកម្ពុជានិងភូមានោះ មានតែបាតដៃទទេក៏ត្រូវអាជ្ញាធរបង្ក្រាប និងបានបង្ក្រាបសាហាវបំផុត ។

ទាំងអាជ្ញាធរភូមា ក៏ដូចជាអាជ្ញាធរខ្មែរដែរ កាលពីពេលគេបង្ក្រាប ទៅលើការធ្វើបាតុកម្មម្ដងៗនោះ,តែងតែមានអង្គការជាតិ និងអន្តរជាតិ ថ្កោលទោស យ៉ាងខ្លាំង ពីព្រោះអ្នកតវ៉ារបស់ប្រទេសទាំងពីរ គឺប្រទេសកម្ពុជា និងភូមានោះ មានតែបាតដៃទទេ ដែលផ្ទុយពីពួកអាវក្រហមនៅសៀម ។

ដូច្នេះហើយបានជាវិធានការរបស់លោក*អាប់ភីស៊ិត* បង្ក្រាបទៅលើពួកអាវក្រហម ដ៏បង្ហូរឈាម កាលពីពេលថ្មីៗនេះមិនសូវមានការថ្កោលទោស ពីអង្គការជាតិ និងអន្តរជាតិ នៅប្រទេសសៀមទេ ដោយគ្រាន់តែមានក្រសួងការបរទេសខ្លះ ដូចជាសហរដ្ឋអាមេរិកបានត្រឹមតែចេញសេចក្ដីថ្លែងការណ៍សំដែងនូវការ សោកស្ដាយ ស្ដីពីអំពើហិង្សានេះតែប៉ុណ្ណោះ ។

**តទៅទំព័រទី៣ ស**

**តមកពីទំព័រទី១ ខ**

ការតវ៉ាដើម្បីបញ្ឈប់សកម្មភាពក្រុមហ៊ុនកុំឱ្យឈូសឆាយតទៅទៀត ។

ប្រជាពលរដ្ឋម្នាក់បានថ្លែងថាប្រជាពលរដ្ឋបាននាំគ្នាធ្វើការហាមឃាត់បុគ្គលិកក្រុមហ៊ុនឱ្យបញ្ឈប់ការឈូសឆាយជាបណ្ដោះអាសន្ន ដើម្បីរង់ចាំគណៈកម្មការខេត្តចុះវាស់វែងឱ្យអ្នកភូមិជាមុនសិន ។ ព្រោះកន្លងមកគណៈកម្មការខេត្តមិនទាន់បានចុះមកធ្វើការវាស់វែងឱ្យប្រជាពលរដ្ឋនៅឡើយទេ ។

ប្រជាពលរដ្ឋដដែលនេះបានបន្តទៀតថា ទោះបីជាប្រជាពលរដ្ឋព្យាយាមរារាំងបុគ្គលិកក្រុមហ៊ុនស្ករសភ្នំពេញរបស់ឧកញ៉ា *លី យ៉ុងផាត់* មិនឱ្យធ្វើការឈូសឆាយយ៉ាងណាក៏ដោយក៏គេនៅតែស្ដាប់ភាសាខ្មែរមិនបានដែរ ។ ផ្ទុយទៅវិញបុគ្គលិកក្រុមហ៊ុនគេអាងកម្លាំងយោធា និងនគរបាលចាំជួយការពារយ៉ាងច្រូងច្រាង ។

តំណាងប្រជាពលរដ្ឋម្នាក់ទៀតឈ្មោះ*ឆមឆត*បាននិយាយយ៉ាងដូច្នេះថា "*កាលពីព្រឹកថ្ងៃសៅរ៍ មានទាហានជាង១៥០នាក់បានលើកមកបន្ថែមទៀត ។ ហើយទាហានទាំងនោះមកពីកងវរសេនាតូចលេខ៣១៣ អតីតកងពលតូចលេខ៣៧ ជាអតីតកងទ័ពខ្មែរក្រហម* " ។

លោក *ឆម ឆត* បានឱ្យដឹងទាំងទោម្នេញទៀតថា "*ខ្ញុំបារម្ភថា ខ្ញុំមិនអាចបញ្ចៀសអំពើហិង្សាបានទេ បើសិនជាបុគ្គលិកក្រុមហ៊ុនមិនស្ដាប់ពួកយើងជាអ្នកភូមិទេនោះ* " ។

មានការកត់សម្គាល់ថាក្នុងឃុំអមលាំង មានភូមិចំនួន១១ និងមានប្រជាពលរដ្ឋសរុបជាង២០០០គ្រួសារកំពុងរងនូវផលប៉ះពាល់ដោយសារក្រុមហ៊ុនស្ករសភ្នំពេញរបស់ឧកញ៉ា *លី យ៉ុងផាត់*ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាលក្នុងទំហំសរុបជាង៩០០០ហិកតា ។

ទាក់ទិននឹងសកម្មភាពទាហានលើកគ្នាកាន់តែច្រើនឡើងៗចូលទៅកាន់ទឹកដីកំពុងមានជម្លោះនេះ ត្រូវបានលោក *អំ សំអាត* មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់របស់អង្គការលីកាដូថ្លែងប្រាប់អ្នកកាសែតកាលពីថ្ងៃសៅរ៍ថាយើងមានការព្រួយបារម្ភបំផុត បើសិនជាពួកគេប្រើប្រាស់ទាហានទាំងនោះដើម្បីការពារប្រយោជន៍ក្រុមហ៊ុន ។ ដូច្នេះអំពើហិង្សាអាចនឹងកើតមានឡើងជាមិនខាន ហើយប្រជាពលរដ្ឋអាចប្រឈមនឹងការចាប់ដាក់គុកសាជាថ្មីទៀតមិនខានឡើយ ។

លោក *អំ សំអាត* នៅតែអះអាងថា "*ប្រការដែលក្រុមហ៊ុនប្រញាប់ប្រញាល់អនុវត្តគម្រោងរបស់ពួកគេបែបនេះគួរតែអាជ្ញាធរបើកការស៊ើបអង្កេតរឿងរ៉ាវឱ្យបានច្បាស់លាស់ ។ ព្រោះពួកគេពុំទាន់ទទួលបានឯកសារគ្រប់គ្រាន់តាមផ្លូវច្បាប់នៅឡើយទេ* " ។

ជាមួយគ្នានេះដែរ លោក *ចាន់ សូវេត* មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៃអង្គការការពារសិទ្ធិមនុស្សអាដហុកបានមានប្រសាសន៍កាលពីថ្ងៃចន្ទម្សិលមិញថា ក្រុមហ៊ុនឯកជនរបស់ *លី យ៉ុងផាត់* បានប្រើប្រាស់កម្លាំងមានសមត្ថកិច្ចដើម្បីការពារផលប្រយោជន៍ឯកជន,ដែលកម្លាំងមានសមត្ថកិច្ចទាំងនោះបើកប្រាក់ខែពីរដ្ឋ ។

លោក *ចាន់ សូវេត* បានបន្តថា កម្លាំងសមត្ថកិច្ចទាំងនោះបានធ្វើជាកម្មករស៊ីឈ្នួលរបស់ក្រុមហ៊ុនទៀត "*ដែលខ្ញុំគិតថាមេបញ្ជាការ ឬរាជរដ្ឋាភិបាលបានបញ្ជាឱ្យកម្លាំងសមត្ថកិច្ចធ្វើអញ្ចឹង ។ វាជារឿងមួយអាប់ឱនដល់កិត្តិយសកងកម្លាំងខ្លាំងណាស់* " ។

លោកបានអត្ថាធិប្បាយថា ក្រុមហ៊ុន *លី យ៉ុងផាត់* នេះមានបញ្ហាច្រើនហើយ ហើយក៏បានប្រើប្រាស់កម្លាំងសមត្ថកិច្ចច្រើនដើម្បីការពារនូវអំពើគំរាមកំហែងប្រជាពលរដ្ឋនោះ ។ វាសាហាវហួស "*យើងខ្ញុំជាសង្គមស៊ីវិលមិនពេញចិត្តចំពោះទង្វើនេះទេ ហើយយើងខ្ញុំក៏មិនគាំទ្រពលរដ្ឋណាដែលទៅកាប់រុករានដីព្រៃរបស់រដ្ឋដែរ តែអាជ្ញាធរគួរពិចារណាទៅលើជីវភាពប្រជាពលរដ្ឋឱ្យបានច្រើនជាងការការពារប្រយោជន៍ឱ្យក្រុមហ៊ុន* " ។

លោក *ចាន់ សូវេត* បានមានប្រសាសន៍ថា ក្រុមហ៊ុនកុំយកពាក្យអភិវឌ្ឍន៍ ហើយត្រូវការកម្មករច្រើនដែលអះអាងថានឹងយកប្រជាពលរដ្ឋទៅធ្វើការនោះ ។តាមពិតទៅនេះជាកាតព្វកិច្ចរបស់ក្រុមហ៊ុន, ព្រោះនៅពេលណាមានក្រុមហ៊ុន គឺត្រូវតែមានកម្មករធ្វើការជាធម្មតា ។ ប៉ុន្តែបើប៉ះពាល់ដីស្រែចំការពលរដ្ឋ គឺត្រូវតែទូទាត់សំណងសមរម្យ មិនមែនជាថ្នូរយកពួកគាត់ទៅធ្វើជាកម្មករអញ្ចឹងទេ ។

លោកថាសមត្ថកិច្ចបានទៅប្រាប់ប្រជាពលរដ្ឋម្ចាស់ដីឱ្យបោះបង់ដីនេះទៅ, កុំដាំដំណាំអ្វីទៀត វានាំតែមានបញ្ហាដាក់ខ្លួនទេ ។ ហើយតាមពិតទៅការវាស់វែងដីនៅឃុំអមលាំងនេះមានការគម្រាមកំហែងប្រជាពលរដ្ឋសម្បើមណាស់ ។ម្យ៉ាងទៀតបើអ្នកណាហ៊ានចេញមុខប្ដឹងគេនឹងចាប់ដាក់គុក ។

ទង្វើបែបនេះ យើង (*ចាន់ សូវេត*) យល់ថា រដ្ឋាភិបាលកម្ពុជាជាពិសេសអ្នកដែលគាំទ្រឱ្យមានការអភិវឌ្ឍន៍ប្រកបដោយទំនាស់យ៉ាងក្ដៅគគុកនេះ គឺយើងមិនគាំទ្រទេ ហើយយើងស្នើសុំឱ្យរដ្ឋាភិបាលពិចារណាឡើងវិញថា គួរតែបណ្ដែតបណ្ដោយឱ្យកើតមានបន្តទៀតឬយ៉ាងណា ?

លោក *ចាន់ សូវេត* បានលើកឡើងថា ដោយសាររង់ចាំការវាស់វែងដីពីសំណាក់អាជ្ញាធរ និងក្រុមហ៊ុន ធ្វើឱ្យប្រជាពលរដ្ឋមិនបានចេញទៅរកស៊ីក៏ត្រូវបង្ខំចិត្តលក់គោ-ក្របីដើម្បីចិញ្ចឹមឆ្នាំង ។ លោកថាប្រជាពលរដ្ឋនៅឃុំអមលាំងលក់គោ-ក្របីស្ទើរអស់ពីភូមិតែម្ដងព្រោះទីមួយពួកគាត់គិតថា បើទុកគោវាគ្មានស្មៅឱ្យស៊ីដោយសារក្រុមហ៊ុនយកដីពួកគាត់អស់ហើយ ។ ទីពីរ បើមិនលក់គោ-ក្របីទេ ពួកគាត់នឹងត្រូវដាច់បាយព្រោះមិនបានចេញទៅរកស៊ីអ្វីសោះ ។

លោក *ចាន់ សូវេត* បញ្ជាក់ច្បាស់ថា ខាងលោកជាសង្គមស៊ីវិលមិនទំនាស់នឹងរឿងអភិវឌ្ឍន៍ទេ តែរដ្ឋាភិបាលត្រូវគិតថាមានតែប្រជាពលរដ្ឋទេដែលរដ្ឋាភិបាលត្រូវគិតគូរ មិនមែនក្រុមហ៊ុនទេ ។ ពីព្រោះប្រទេសមួយដែលមានប្រជាពលរដ្ឋគាំទ្ររដ្ឋាភិបាលទើបរដ្ឋាភិបាលនោះដំណើរការទៅបាន ។ តែបើប្រជាពលរដ្ឋមិនគាំទ្ររដ្ឋាភិបាលវិញ តើរដ្ឋាភិបាលដំណើរការទៅរួចដែរ ឬទេ ?

ទំនាស់ដីធ្លីនៅឃុំអមលាំងស្រុកថ្ពង ខេត្តកំពង់ស្ពឺនេះ ដូចជាពុំទាន់មានដំណោះស្រាយណាមួយសមស្របគួរនឹងទទួលយកបានសោះ ៕

**តមកពីទំព័រទី២ ស**

ទោះជាយ៉ាងណាក៏មានសារព័ត៌មាន នៃប្រទេសជិតខាងប្រទេសសៀមខ្លះ ដែលនិយមពួកចាញ់ (ក្រុមអាវក្រហម) បាននិយាយ អំពីសកម្មភាព ដ៏សាហាវ របស់*អាប់ភីស៊ិត* ដោយភ្លេចនិយាយអំពីអាជ្ញាធររបស់ខ្លួន ប្រើអំពើហិង្សា បង្ក្រាបបាតុករជាជនស៊ីវិល និងជាព្រះសង្ឃ ដែលមានតែបាតដៃទទេតវ៉ាទាមទាររកយុត្តិធម៌ ពីការលួចបន្លំ សន្លឹកឆ្នោត របស់អាចារ្យ*ឆេងផុន*កាលពីឆ្នាំ១៩៩៨នោះ ។

ដោយឃើញ នូវសកម្មភាពដ៏សាហាវ របស់ទាហានសៀមបង្ក្រាបទៅលើបាតុករអាវក្រហមដែលបណ្ដាលឱ្យមានអ្នកស្លាប់ដល់ទៅ៨៣នាក់ និងរបួសជាង ១.៨០០នាក់នោះបានធ្វើឱ្យអ្នកឃើញព្រឹត្តិការណ៍ របស់កម្លាំងអាជ្ញាធរខ្មែរ និងអាជ្ញាធរភូមាបង្ក្រាប ទៅលើ អ្នកតវ៉ាកន្លងមកនោះ ដាក់ប្រទេសសៀមលំដាប់លេខ៣បន្ទាប់ពីកម្ពុជា និងភូមា ។ ដូច្នេះ នៅក្នុងតំបន់អាស៊ីយើងនេះ មានប្រទេស៣ ហើយដែលលេចធ្លោក្នុងការដឹកនាំកម្លាំងបង្ក្រាប ទៅលើអ្នកតវ៉ាដោយបង្ហូរឈាមនោះគឺប្រទេសភូមា ប្រទេសកម្ពុជា និងប្រទេសសៀម ។ ប្រទេសភូមាក្រោមការដឹកនាំ របស់លោកឧត្តមសេនីយ៍*ថាន់ ស្វេ*, ប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់នាយឧត្តមសេនីយ៍ ផ្កាយមាស ៥ផុតលេខ*ហ៊ុន សែន* និងនៅប្រទេសសៀមគឺ*អាប់ភីស៊ិត វ៉ាចាជីវ៉ា* ។

ទោះបីជា យ៉ាងណាក៏ដោយ រាល់ការបង្ក្រាប ដោយអាវុធផ្ដាច់ជីវិតបាតុករ ត្រូវបានថ្កោលទោស ពីសំណាក់ប្រជាពលរដ្ឋក៏ដូចជាអន្តរជាតិជៀសមិនផុតឡើយ ៕

**តមកពីទំព័រទី៤ ឡ**

ទៅចាំយកលិខិត អនុញ្ញាតនៅក្រសួងមហាផ្ទៃ រហូតដល់ពេលល្ងាច គឺទាល់តែមាន បិទភ្លើងនៅបន្ទប់ធ្វើការទៀតផង ។

នៅពេលដែលសួរថាតើគណបក្សសម រង្ស៊ីនឹងមានវិធានការអ្វីផ្សេងទេ បើការបដិសេធ មិនឱ្យចូលសួរសុខទុក្ខអ្នករងគ្រោះទាំង២រូបនេះនៅតែបន្តនោះ ? លោកស្រី*កែ សុវណ្ណរតន៍* បានមានប្រសាសន៍ថា "*យើងនៅតែព្យាយាម ។ យើងគិតថា គ្មានរឿងអីដែលក្រសួងមហាផ្ទៃធ្វើការរារាំងមិនអោយអ្នកតំណាងរាស្ត្រ ដែលកើតឡើង ដោយប្រជាពលរដ្ឋមិនបានទៅសួរសុខទុក្ខប្រជាពលរដ្ឋទេព្រោះយើងដឹងថា ជាទូទៅប្រជាពលរដ្ឋជាអ្នកដែលទទួលបានការយកចិត្តទុកដាក់ពីតំណាងរាស្ត្រ ពីរដ្ឋាភិបាល ពីអង្គការក្រៅរដ្ឋាភិបាល ហើយនេះ ក៏មិនមែនជាលើកទីមួយ ដែលគណបក្សសម រង្ស៊ីទៅសួរសុខទុក្ខលោកស្រី មាស ស្រី និងលោកព្រំ ជាទេ គឺជាលើកទី៣ហើយ ដែលយើងត្រូវទៅសួរសុខទុក្ខ ។ ក៏ប៉ុន្តែ បើទោះបីជា យ៉ាងណាក៏ដោយ ក៏យើងនៅតែព្យាយាម ហើយតស៊ូបន្ថែមទៀត ដើម្បីទៅសួរសុខទុក្ខពួកគាត់ ហើយយើងក៏ស្នើឱ្យក្រសួងមហាផ្ទៃពិចារណាឡើងវិញចំពោះការហាមឃាត់នេះ* " ។

ចំពោះសំណួរ ដែលសួរថាតើប្រតិភូគណបក្សសម រង្ស៊ី មានផែនការសួរសុខទុក្ខ ប្រជាពលរដ្ឋដែលរងគ្រោះដទៃទៀត ដូចករណីលោកស្រី*មាស ស្រី* និងលោក*ព្រំ ជា*ដែរឬទេ ។ លោកស្រី*កែ សុវណ្ណរតន៍* បានមានប្រសាសន៍ថា គណៈប្រតិភូ គណបក្សសម រង្ស៊ី តែងតែបានទៅសួរសុខទុក្ខ ប្រជាពលរដ្ឋ និងអ្នកសារព័ត៌មានដែលរងគ្រោះដោយអំពើអយុត្តិធម៌ ពិសេសដូចជាប្រជាពលរដ្ឋ ដែលខ្លះរងគ្រោះ ដោយគេរំលោភយកដីពួកគាត់ហើយត្រូវបានអាជ្ញាធរចាប់ដាក់ពន្ធនាគារនោះ ។

លោកស្រី អគ្គលេខាធិការគណបក្សសម រង្ស៊ី រូបនេះបានបន្តទៀតថា បើសិនជា អាជ្ញាធរនៅតែហាមឃាត់មិនអោយគណៈប្រតិភូ ចូលជួប សួរសុខទុក្ខ លោកស្រី*មាស ស្រី* និងលោក*ព្រំ ជា*ទេនោះ គណៈប្រតិភូគណបក្សសម រង្ស៊ី នឹងទៅសួរសុខទុក្ខ ក្រុមគ្រួសារ របស់ពួកគាត់ នៅលំនៅដ្ឋាន ដោយមានការនាំយក ចំណីអាហារ ថ្នាំសង្កូវ ព្រមទាំងថវិកា សំរាប់ក្រុមគ្រួសារពួកគាត់ផងដែរ ។

សូមបញ្ជាក់ថា លោក*ព្រំ ជា* និងអ្នកស្រី*មាស ស្រី*ជាកសិករ ២រូប ក្នុងចំណោមកសិករ ជាច្រើននាក់ ដែលបាត់បង់ដីស្រែដោយសារ ការបោះបង្គោលព្រំដែន រវាងកម្ពុជា ជាមួយយួននៅតម្រុយបង្គោលព្រំដែនលេខ ១៨៥ ។

អ្នកទាំងពីររូប បានចូលរួមក្នុងចលនា ដកតម្រុយបង្គោលព្រំដែនលេខ១៨៥នោះ ជាមួយលោក*សម រង្ស៊ី* ហើយត្រូវបានតុលាការសាលាដំបូងខេត្តស្វាយរៀង កាត់អោយជាប់ពន្ធនាគារម្នាក់ៗ១ឆ្នាំ និងពិន័យជាប្រាក់រាប់លានរៀលទៀតហើយតុលាការដដែលនេះក៏បានកាត់ក្ដី ឱ្យលោក*សម រង្ស៊ី* ជាប់ពន្ធនាគារ២ឆ្នាំនិងពិន័យជាប្រាក់រាប់សិបលានរៀលទៀតនោះ ។

មជ្ឈដ្ឋាននានាបានសំដែងនូវការសោកស្ដាយថាលោក*ព្រំជា* និងលោកស្រី*មាសស្រី* បាត់បង់ដីស្រែហើយ ត្រូវអាជ្ញាធរខ្មែរចាប់ដាក់ពន្ធនាគារយ៉ាងអយុត្តិធម៌ទៀត ៕



គណបក្ស សម រង្ស៊ី
SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

សេចក្ដីអំពាវនាវ

គណបក្ស សម រង្ស៊ី សូមជំរាបជូនដំណឹងដល់សមាជិក-សមាជិកាគណបក្ស និងបងប្អូនសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេសទាំងអស់ ឱ្យបានជ្រាបថា លោកស្រី **មាស ស្រី** និងលោក **ព្រំ ជា** ជាប្រជាពលរដ្ឋរស់នៅភូមិកោះក្បាលខាងជើង ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានតុលាការខេត្តស្វាយរៀង ចាប់ឃុំខ្លួនដាក់ក្នុងពន្ធនាគារយ៉ាងអយុត្តិធម៌ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ដោយចោទប្រកាន់ពីបទ **ធ្វើឱ្យខូចខាតដោយចេតនានូវតម្រុយបង្គោលព្រំដែន លេខ ១៨៥** កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ។ លោកស្រី **មាស ស្រី** និងលោក **ព្រំ ជា** គឺជាម្ចាស់ដីស្រែ ក្នុងចំណោមម្ចាស់ដីស្រែដទៃទៀត ដែលបានបាត់បង់ដីស្រែដោយការបោះតម្រុយបង្គោលព្រំដែន លេខ ១៨៥ ចូលក្នុងដីស្រែរបស់ពួកគាត់ ។

*សូមទស្សនារូបភាពវីដេអូ សង្ខេប :* http://tinyurl.com/ylwf289 , http://tinyurl.com/yfmakb5

តាងនាមឱ្យក្រុមគ្រួសារជនរងគ្រោះ និងតាងនាមឱ្យគណបក្ស សម រង្ស៊ី ខ្ញុំសូមអំពាវនាវដល់សមាជិក-សមាជិកាគណបក្ស និងបងប្អូនសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេសទាំងអស់ មេត្តាជួយឧបត្ថម្ភតាមលទ្ធភាព និងសមានចិត្ត ដែលបងប្អូនអាចធ្វើទៅបាន ដើម្បីជួយលើកទឹកចិត្ត គាំទ្រ និងសំរាលបន្ទុកដល់ក្រុមគ្រួសាររបស់លោកស្រី **មាស ស្រី** និងលោក **ព្រំ ជា** ដែលបានរងគ្រោះដោយការបាត់បង់ដីស្រែ ពីការបោះតម្រុយបង្គោលព្រំដែន លេខ ១៨៥ ចូលក្នុងដីស្រែរបស់ពួកគាត់ ដោយក្ដីអនុគ្រោះ ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុត ដល់សមាជិក-សមាជិកាគណបក្ស និងបងប្អូនសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេសទាំងអស់ ដែលតែងតែលះបង់នូវធនធានផ្ទាល់ខ្លួន ជួយឧបត្ថម្ភដល់បងប្អូនជនរងគ្រោះ ក្នុងបុព្វហេតុតស៊ូដើម្បីការពារផលប្រយោជន៍ជាតិ បូរណភាពទឹកដី លទ្ធិប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម ។

ខ្ញុំសូមជូនពរដល់សមាជិក-សមាជិកាគណបក្ស និងបងប្អូនសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេសទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំង បួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩
អគ្គលេខាធិការគណបក្ស
K. Sovann
កែ សុវណ្ណរតន៍

Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
E-mail address : srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍
ផ្សព្វផ្សាយពាណិជ្ជកម្ម លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក
សូមទាក់ទងមកកាន់
ទូរស័ព្ទ : 017 360 678
ទូរសារ : 023 987 411
E-mail : kmsnews@gmail.com

ក្រុមហ៊ុនភាពយន្ត
ជនបទ
មានទទួលបញ្ចាំង
ខ្សែភាពយន្តខ្នាតធំ
ក្នុងពិធីផ្សេងៗ
មានពន្លឺច្បាស់
និងមានលក់ម៉ាស៊ីន
បញ្ចាំងខ្សែភាពយន្ត
ទំនាក់ទំនងតាមទូរស័ព្ទ
012 66 44 67
015 66 44 67

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
Tel: 017 360 678 , E-mail: kmsnews@gmail.com

**តមកពីទំព័រទី១ ម**

គ្មានសមត្ថភាពការងារ ។

លោកគង់ គាំ ប្រធានស្តីទី គណបក្សសម រង្ស៊ី កាលពីថ្ងៃច័ន្ទ ទី២៤ ឧសភា ឆ្នាំ២០១០ បានប្រាប់ *ខ្មែរម្ចាស់ស្រុក* បែបឡុកឡឺយថា លោកឱម យ៉ិនទៀង គួរតែត្រូវបាន តែងតាំងអោយធ្វើជាប្រធាន អង្គភាពការពារជនពុករលួយវិញ ល្អប្រសើរជាង ។ លោកបានមានប្រសាសន៍ថា អំពើពុករលួយ គឺជាកង្វល់ របស់ប្រជាពលរដ្ឋខ្មែរយើង ។

លោកគង់ គាំ បានមានប្រសាសន៍ថា "*អំពើពុករលួយ ជាឧក្រិដ្ឋកម្ម បង្កមហន្តរាយ មិនខុសពី អំពើប្រល័យពូជសាសន៍កន្លងមកទេ ។ ពីមុនមក មានឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍នៅកម្ពុជា ។ ក៏ប៉ុន្តែឥឡូវនេះ មានឧក្រិដ្ឋកម្មមួយទៀតដែលសាហាវដូចគ្នាហ្នឹង គឺអំពើពុករលួយ នាំឱ្យវិនាស នាំឱ្យហិនហោច នាំឱ្យក្រីក្រ នាំឱ្យស្លាប់ដូចគ្នា*" ។

ប្រធានស្តីទី គណបក្សសម រង្ស៊ី រូបនេះក៏បានរិះគន់ទៅលើរដ្ឋាភិបាល ដែលជាស្ថាប័ន នីតិប្រតិបត្តិជម្រុញអោយរដ្ឋសភាដែលជាស្ថាប័ន នីតិបញ្ញត្តិអនុម័តឱ្យបានឆាប់នូវច្បាប់ប្រឆាំងអំពើពុករលួយកន្លងមក ។ ជាមួយគ្នានោះដែរ លោកក៏បានដឹងជាមុនថា លោកឱម យ៉ិនទៀង នឹងត្រូវបានគេតែងតាំងជាប្រធានអង្គភាព ប្រឆាំងនឹងអំពើពុករលួយនេះ ។ ឥឡូវគេតែងតាំង ដូចការគិតទុក របស់លោកមែន ។

លោកឱម យ៉ិនទៀង ជាទីប្រឹក្សាពិសេស លោកនាយករដ្ឋមន្ត្រីហ៊ុន សែន និងក៏ជាប្រធានសិទ្ធិមនុស្សរដ្ឋាភិបាល ផងដែរ ។ កន្លងមកមានគេរិះគន់លោកឱម យ៉ិនទៀង ថា មិនមែនជាប្រធានសិទ្ធិមនុស្ស រដ្ឋាភិបាលទេ តែគាត់ជាប្រធានសំរាប់ជួយបិទបាំង អ្នករំលោភសិទ្ធិមនុស្សនៅកម្ពុជា ។

លោកគង់ គាំ បានមានប្រសាសន៍ថា "*អ្នកជំនាញ ពិភពលោកគេប្រតិកម្មថា មិនដែលមានអ្នកណា យកអ្នកមាន អំណាច ឬមនុស្សរបស់រាជរដ្ឋាភិបាល ទៅធ្វើជាមេប្រឆាំងអំពើពុករលួយទេ ។ ដូច្នេះយើងដឹងខ្លះហើយ សកម្មភាព និងផ្ទៃផ្កា របស់គាត់ គឺជាអ្នកបិទបាំងសព្វយ៉ាងទាំងអស់កាលកន្លងមក ។ ឱម យ៉ិនទៀង ធ្វើសិទ្ធិមនុស្ស ជួយបិទបាំង ការរំលោភសិទ្ធិមនុស្សនៅកម្ពុជា, ហើយបើធ្វើប្រធានពុករលួយវិញទៀត គឺគាត់ត្រូវបិទបាំងអំពើពុករលួយនៅប្រទេសកម្ពុជា ។ នេះខ្ញុំមានជំនឿអញ្ចឹងមានហេតុមានផលជាក់ស្តែង, ដូច្នេះខ្ញុំជឿថាយើងអត់មាន សេចក្តីសង្ឃឹម និងជំនឿថា អំពើពុករលួយ នឹងថមថយ ហើយសកម្មភាព របស់ឱម យ៉ិនទៀងហ្នឹង ជួយលុបបំបាត់ឬកាត់បន្ថយអំពើពុករលួយបានទេ ហើយវាកាន់តែ លើកទឹកចិត្ត ធ្វើអោយមានអំពើពុករលួយហ្នឹង កាន់តែរាលដាល ធំធេងតទៅទៀត*" ។

ការថ្លែងចំអក របស់លោកគង់ គាំ នេះ ទំនងជាគាត់ គិតដល់ប្រសាសន៍ របស់លោកស្រី ខារ៉ូល រ៉ដលី ឯកអគ្គរដ្ឋទូតអាមេរិក ដែលធ្លាប់បានថ្លែងថា អំពើពុករលួយនៅកម្ពុជា បានធ្វើឱ្យបាត់បង់ថវិកាចំណូលរដ្ឋ ប្រមាណ៥០០លានដុល្លារ នៅក្នុងមួយឆ្នាំៗ ។ ការថ្លែងរបស់ឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំក្រុងភ្នំពេញនេះ បានធ្វើឱ្យមន្ត្រីរដ្ឋាភិបាល ជាពិសេសលោក ឱម យ៉ិនទៀង មានប្រតិកម្មខ្លាំងៗ ឆ្លើយតបទៅលោកស្រីវិញ និងក៏មានក្រុមកំប្លែង នៅតាមស្ថានីយ៍ទូរទស្សន៍នានា សំដែងប្រឆាំងនឹងសម្តីរបស់លោកស្រីផងដែរ ។

លោកឱម យ៉ិនទៀង ធ្លាប់ត្រូវបានលោកហ៊ុន សែន តែងតាំងជាប្រធានគណៈកម្មការប្រឆាំងអំពើពុករលួយ ម្តងហើយ កាលពីឆ្នាំ២០០៦ ។ នៅចុងឆ្នាំ២០០៦ លោកឱម យ៉ិនទៀង បានបើក ប្រតិបត្តិការ បង្ក្រាបអ្នករកស៊ី នាំរថយន្តចង្កូតស្តាំពីប្រទេសជិតខាងចូលកម្ពុជា ។

ប្រតិបត្តិការនោះមានឈ្មោះថា "*ប្រតិបត្តិការបុណ្យអុំទូកឆ្នាំ២០០៦*" ដែលកាលណោះលោកឱម យ៉ិនទៀង ចាប់អ្នកនាំរថយន្តចង្កូតស្តាំជាច្រើននាក់ ដាក់ពន្ធនាគារបានមួយដង្ហើមចង្រិតដោយរួមទាំង ប្រមូលបាន រថយន្ត នៅតាមឃ្លាំងនានាទៀតផង ។ ជាមួយគ្នានោះ លោកឱម យ៉ិនទៀង ក៏បានជម្រុញឱ្យមានការ ដកហូតតំណែង មន្ត្រីគយ នៅព្រំដែនខាងលិច និងមន្ត្រីប៉ូលិស ខេត្តបន្ទាយមានជ័យ ជាង៣០នាក់ផងដែរ ។

ដូច្នេះ គេរង់ចាំមើលថា តើលោកឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មីនេះអាចនឹងវែកមុខ មន្ត្រីពុករលួយបានដែរឬទេ បើថ្មីៗនេះលោកង៉ោ ហុងលី មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីរកឃើញមានឈ្មោះមន្ត្រីខ្មោច ជាង ២.០០០ នាក់ ដែលធ្វើឱ្យខាតបង់ ថវិកាជាតិប្រមាណជាង២លានដុល្លារក្នុងមួយឆ្នាំនោះ ។

ទោះជាយ៉ាងណាមានមតិជាច្រើននិយាយថាលោកឱម យ៉ិនទៀង នឹងមិនអាច បំបាត់អំពើពុករលួយបានទេ, ហើយគាត់ក៏មិនអាចមានវិធានការ ទៅលើមន្ត្រីពុករលួយ ធំៗបានដែរ ។ ដូច្នេះហើយ បានជាលោក គង់ គាំ ប្រធានស្តីទី គណបក្សសម រង្ស៊ី មានប្រសាសន៍ថា លោកឱម យ៉ិនទៀង មិនអាចធ្វើជាប្រធាន អង្គភាពប្រឆាំង អំពើពុករលួយបានទេ ។ ប៉ុន្តែគាត់គួរតែធ្វើជាប្រធានអង្គភាពការពារជនពុករលួយវិញល្អជាង ៕




**តមកពីទំព័រទី១ ឡ**

នៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ វេលាម៉ោង១០ ព្រឹក នៅពន្ធនាគារខេត្តស្វាយរៀង ។

លិខិតដែលបានចុះហត្ថលេខាដោយលោកហួរ វ៉ាន់ អគ្គលេខាធិការរង និងក៏ជា អ្នកតំណាងរាស្ត្រ មណ្ឌលភ្នំពេញ ស្នើទៅលោកស ខេង ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី២៤ ឧសភា ឆ្នាំ២០១០ បានសរសេរថា កាលពីថ្ងៃទី២៧ខែមករា ឆ្នាំ២០១០ លោកស្រីមាស ស្រី និងលោកព្រាំ ជា ជាប្រជាកសិករ នៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀងត្រូវបានសាលាដំបូងខេត្តស្វាយរៀងធ្វើការ ចោទប្រកាន់ និងផ្តន្ទាទោសពីបទធ្វើឱ្យខូចខាតដោយចេតនា ( តម្រុយ បង្គោលព្រំដែនលេខ១៨៥) ហើយសំណុំរឿងនេះ ក៏ត្រូវបានបញ្ជូនមកសាលាឧទ្ធរណ៍រួចហើយ ។

ប្រតិភូអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីដែលនឹងត្រូវចូលជួបសួរសុខទុក្ខ លោកស្រីមាស ស្រី និងលោកព្រាំ ជា មានក្នុងបញ្ជីភ្ជាប់ជូនជាមួយ ។

គណៈប្រតិភូ ជាអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ធ្លាប់បានចូលជួប សួរសុខទុក្ខ ប្រជាពលរដ្ឋរងគ្រោះ ទាំង២រូបនេះ ចំនួន២លើកមកហើយ ។ ប៉ុន្តែការសុំទៅជួប សួរសុខទុក្ខដែលមានលក្ខណៈធម្មតា ដូចមុនជាលើកទី៣នេះ បានសុំចំនួន ៣ ដងហើយ នៅតែមិនទាន់ មានការឆ្លើយតប ។

លោកស្រី កែ សុវណ្ណរតន៍ អគ្គលេខាធិការ គណបក្សសម រង្ស៊ី បានប្រាប់ ក្រុមអ្នកសារព័ត៌មាននៅទីស្នាក់ការកណ្តាល គណបក្សសម រង្ស៊ី ក្រុងភ្នំពេញ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ម្សិលមិញយ៉ាងដូច្នេះថា "*យើងបានធ្វើលិខិតចំនួន៣ដង ហើយគឺត្រូវបានបដិសេធដោយរដ្ឋាភិបាល ។ ខ្ញុំមានការសោកស្តាយ, ប៉ុន្តែយើងមិនរាថយទេ យើងនៅតែបន្ត ក្នុងការ ដាក់លិខិតទៅក្រសួងមហាផ្ទៃ ជាបន្តទៀត ពីព្រោះនេះជាកាតព្វកិច្ចរបស់អ្នកតំណាងរាស្ត្រដែលត្រូវតែដឹង អំពីសុខទុក្ខ របស់ប្រជាពលរដ្ឋ, ហើយគាត់ជាប្រជាពលរដ្ឋ ដែលរងគ្រោះដោយការបាត់បង់ដីធ្លីផង ហើយក៏ជាការងារមួយដែលបង្ហាញថាគាត់រួមចំណែក ក្នុងការការពារទឹកដីកម្ពុជាដែរ ។ ពីព្រោះពួកគាត់ជាប់ពន្ធនាគារនេះគឺជាប់ពន្ធនាគារដោយសារការបោះបង្គោលតម្រុយព្រំដែន ចូលមកក្នុង ដីស្រែរបស់គាត់ ដែលគាត់ បានកាន់កាប់ជាយូរឆ្នាំមកហើយ*" ។

មានបណ្តាញព័ត៌មានខ្លះអះអាងថា ក្រសួងមហាផ្ទៃ បានឆ្លើយតបហើយ ។ បញ្ហានេះ លោកស្រីកែ សុវណ្ណរតន៍ បានមានប្រសាសន៍ថា "*ចម្លើយនេះគឺជាចម្លើយមួយ ដែលគ្មានការទទួលខុសត្រូវ ពីព្រោះថា ប្រព័ន្ធរដ្ឋបាលកាលណាលិខិតរបស់ស្ថាប័នមួយដាក់ទៅស្ថាប័នមួយដល់កន្លែង ស្ថាប័ននោះ ត្រូវផ្ញើលិខិតមកដល់កន្លែងហ្នឹងវិញ គឺមិនមែន ត្រូវឱ្យអ្នកដាក់លិខិតហ្នឹង ទៅយកនៅក្រសួងមហាផ្ទៃទេ*" ។

ចំពោះចម្លើយដែលថា គណបក្សសម រង្ស៊ី មិនបានទៅយកនោះ ក៏ផុយដែរ ពីព្រោះកាលពីថ្ងៃទី១៩ ឧសភា ឆ្នាំ២០១០, មន្ត្រីគណបក្សសម រង្ស៊ី បាន

**តនៅទំព័រទី៣ ឡ**

**តមកពីទំព័រទី១ ក**

**ទាំងឡាយ រាប់ទាំងក្រុមហ៊ុនឯកជនជាប្រពន្ធរបស់មន្ត្រីធំៗផងដែរ។ មានករណីមួយនៅភូមិឡពាង ឃុំតាចេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលប្រជារាស្ត្រជាង១រយគ្រួសារនៅតែធ្វើការតវ៉ាជាង១០ឆ្នាំមកហើយតទល់នឹងក្រុមហ៊ុនខេប៊ីស៊ី របស់អ្នកស្រីជា ខេងប្រពន្ធរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស៊ុយ សែម។**

**តើរឿងរ៉ាវនោះវាយ៉ាងណា ឬមួយវាគឺជាការបង្ហាញអសមត្ថភាពផង និងកង្វះឆន្ទៈផងរបស់រដ្ឋាភិបាលបក្សប្រជាជន ឬនិយាយឱ្យចំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន នៃគណបក្សត្រួតត្រាប្រទេសនេះ ដែលវិបត្តិដីធ្លីចេះតែបន្តរីករាលដាល ហើយករណីនៅភូមិឡពាង ខេត្តកំពង់ឆ្នាំងនោះ ទំនាស់បានកើតមានតាំងពីជាង១០ឆ្នាំមកហើយនោះ ? គេពិតជាមិនពិបាកយល់នោះទេថា បើប្រជារាស្ត្រមានមូលដ្ឋាន និងមូលហេតុច្បាស់លាស់ដើម្បីអះអាងថា ដីទាំងនោះជារបស់ពួកគាត់ទេ ម្ល៉េះសមពួកគាត់មិនប្រថុយផ្សងគ្រោះថ្នាក់ចេញមុខតវ៉ា ប្រឈមនឹងការចាប់ដាក់ពន្ធនាគារដោយអំណាចឥទ្ធិពលលុយ និងតំណែងរបស់អ្នកស្រី ជា ខេង និងស្វាមីគាត់បែបនេះឡើយ ។ ហើយចុះបើយ៉ាងនេះ ហេតុអ្វីក៏រដ្ឋាភិបាលបក្សប្រជាជននៃនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានបង្ហាញខ្លួនថា ជាអ្នកត្រួតត្រាប្រទេសដូច្នេះមានកាតព្វកិច្ចត្រូវរកការពិត និងយុត្តិធម៌ជូនប្រជារាស្ត្រកសិករជាម្ចាស់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវដើម្បីបញ្ចប់ការតវ៉ារបស់ពួកគាត់ជាង១០ឆ្នាំមកនេះ ?**

**រឿងរ៉ាវនេះអាជ្ញាធរថ្នាក់ខេត្ត ថ្នាក់ស្រុក ដូចជាដឹងខ្លួនមិនខុសអ្វីពីការកត់សម្គាល់របស់លោក នី ចរិយា អ្នកស្រាវជ្រាវនៃសមាគមសិទ្ធិមនុស្សអាដហុកដែលបានអធិប្បាយថាពួកមន្ត្រីអាជ្ញាធរថ្នាក់ខេត្តបានប្រាប់ក្រុមសិទ្ធិមនុស្សថាករណីជម្លោះដីធ្លីខ្លះ ពួកគេអាជ្ញាធរមិនហ៊ានប៉ះទេ ពីព្រោះម្ចាស់ជាក្រុមហ៊ុនរបស់អ្នកមានអំណាច។ ហើយនេះវាមិនជាការខុសអ្វីនឹងករណីរបស់ប្រជារាស្ត្រជាង១រយគ្រួសារដែលហ៊ានប្រឈមតវ៉ាទល់នឹងក្រុមហ៊ុនខេប៊ីស៊ី របស់អ្នកស្រី ជា ខេង ក្នុងពេលដែលអាជ្ញាធរឃុំ ស្រុក ខេត្តកំពង់ឆ្នាំងខ្លួនឯងមិនអាចនឹងបំពេញតួនាទីដើម្បីដោះស្រាយបញ្ចប់បញ្ហានៃភាពរងគ្រោះដ៏អយុត្តិធម៌របស់ប្រជារាស្ត្រទាំងនោះឡើយ ។**

**និយាយអំពីបញ្ហានេះ ស្តាប់ការប្រើភាសាវិលវល់របស់អ្នកស្រី ជា ខេង នៅឯពិធីមួយដែលមានការចូលរួមរបស់ប្រជារាស្ត្រនោះ វាដូចជាថា ប្រពន្ធរដ្ឋមន្ត្រីរូបនេះមានឥទ្ធិពលអំណាចខ្លាំង ល្មមតែអាជ្ញាធរថ្នាក់ស្រុក ថ្នាក់ខេត្តព្រឺរោមចុះញ៉មមិនហ៊ានតវ៉ា និងការពារយុត្តិធម៌ជូនប្រជារាស្ត្រ។ ក្នុងសម្តីវិលវល់របស់គាត់នោះ អ្នកស្រី ជា ខេង បាននិយាយថា "បើមានកម្មសិទ្ធិឱ្យស្របច្បាប់ យកមកខ្ញុំឱ្យ ដីដែលអ្នកស្រុកតវ៉ា។ បើជជែកពីកេរ្តិ៍ដូនតាណាមក ខ្ញុំអត់ត្រូវការស្តាប់ទេ។ ខ្ញុំត្រូវការតែផ្លូវច្បាប់។ ដូច្នេះអ៊ីៗទាំងអស់ អង្គការទាំងអស់ត្រូវជ្រាបថា ខ្ញុំមិនអាចឱ្យបានទេ។ អញ្ចឹងខ្ញុំអាចផ្តិតមេដៃទៅយកផ្ទះលោកនេះឥឡូវក៏បានដែរ។ ខ្ញុំទៅយកផ្ទះតែម្តង។ ខ្ញុំមិនហៅប៉ុណ្ណឹងនាក់ទេ ខ្ញុំហៅ៥រយនាក់ផ្តិតយកផ្ទះលោកឯង បើលោកឯងទទួលស្គាល់ឯកសារប៉ុណ្ណឹង!... "។**

**ពិតជាធ្វើឱ្យព្រឺព្រួចសម្បើមណាស់ពេលបានឮសម្តីរបស់អ្នកស្រី ជា ខេង ប្រពន្ធរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស៊ុយ សែម នោះ។ គេអាចលើកជាសំណួរថា តើអ្នកស្រីជា ខេង ពិតជាស្រឡាញ់យុត្តិធម៌ ហើយលោករដ្ឋមន្ត្រី ស៊ុយ សែម ជាស្វាមីពិតជាចង់ដឹងការពិត និងជួយប្រជារាស្ត្រម្ចាស់សន្លឹកឆ្នោតដោយផ្អែកលើស្មារតីយុត្តិធម៌មិនលោភលន់ មិនកេងប្រវ័ញ្ចមែន ឬយ៉ាងណា ?**

**បើពិតជាយ៉ាងនេះ បើរដ្ឋមន្ត្រី ស៊ុយ សែម ស្រឡាញ់កិត្តិយស បើប្រពន្ធរបស់គាត់អ្នកស្រី ជា ខេង ពិតជាមិនខ្លាចការពិត ហើយចង់បានយុត្តិធម៌ជូនពលរដ្ឋ នោះគេនឹងអាចរកដំណោះស្រាយ បានយ៉ាងងាយបំផុត។ គឺវាដូចករណីដែលមន្ត្រីអង្គការសមាគមការពារសិទ្ធិមនុស្សអាដហុកបានអធិប្បាយថា ប្រជារាស្ត្រសហគមន៍ក៏ជាអ្នករងគ្រោះ ហើយអ្នកស្រី ជាខេង ខ្លួនឯងក៏ជាអ្នករងគ្រោះ។ ដូច្នេះតើនរណាជាអ្នកបង្កើតភាពរងគ្រោះរបស់ភាគីទាំងពីរ?**

**ច្បាស់ណាស់ថា គេត្រូវវែកមុខរកថា តើអ្នកស្រី ជាខេង នោះបានទិញដីពីនរណា តាមនីតិវិធីស្របច្បាប់ ឬមួយក៏អាងតំណែងតួនាទីរបស់ប្តី និងអាងឥទ្ធិពលលុយកាក់ធ្វើឱ្យជញ្ជីងយុត្តិធម៌ និងច្បាប់ដើម្បីបានរបស់ដែលហៅថាឯកសារស្របច្បាប់ជាម្ចាស់កម្មសិទ្ធិដីធ្លី ជាដីធ្លីដែលកាន់កាប់ដោយប្រជារាស្ត្រតាំងពីណាពីណើ ដូច្នេះប្រជារាស្ត្រក៏ជាម្ចាស់ស្របច្បាប់តាមច្បាប់ភូមិបាលឆ្នាំ២០០១របស់កម្ពុជានោះ ?**

**និយាយទៅបញ្ហានេះមិនពិបាកដោះស្រាយនោះទេ បើអ្នកស្រី ជា ខេង ប្រពន្ធរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ស៊ុយ សែម ពិតជាចង់ដឹងការពិត ហើយស្រឡាញ់យុត្តិធម៌នោះ។ រឿងនេះបើរំពឹងលើការដោះស្រាយរបស់នាយករដ្ឋមន្ត្រី ដូចឱ្យប្រជារាស្ត្ររំពឹងលើផ្កាយលើមេឃដូច្នោះដែរ ពីព្រោះជាង១០ឆ្នាំ មិនមែនប្រមុខរដ្ឋាភិបាលមិនដឹងបញ្ហានេះទេ ប៉ុន្តែហេតុអ្វីគាត់មិនមានសមត្ថភាពនឹងដោះស្រាយ ? គឺមកពីភាគីជម្លោះអ្នកស្រី ជា ខេង មានស្វាមីជារដ្ឋមន្ត្រី ស៊ុយ សែម ជាមន្ត្រីជាន់ខ្ពស់របស់គណបក្សប្រជាជន ហើយបើនឹងចេញមុខជំរុញឱ្យមានការអនុវត្តច្បាប់ដោយត្រឹមត្រូវ និងធ្វើការស៊ើបអង្កេតច្បាស់លាស់ បើដោះស្រាយក្នុងករណីដែលលោក ស៊ុយ សែម ចាញ់ក្តីចំពោះមុខប្រជារាស្ត្រច្បាស់ណាស់ថា វានឹងបាក់មុខដល់គណបក្សប្រជាជន ទាំងនាយករដ្ឋមន្ត្រីខ្លួនឯងផងដែរមិនសមបើនឹងបណ្តោយឱ្យខ្លួនជាប់ផុងនៅក្នុងជម្លោះដីធ្លីជាមួយប្រជាកសិករនោះទេ៕**